# ការប្រាស្រ័យទាក់ទង និងការចេះដឹងទូទៅ (កូនក្មេងអាយុ៣-៥ឆ្នាំ)

ការប្រាស្រ័យទាក់ទងទាក់ទិននឹងការនិយាយ និងការស្តាប់ទាំងពីរ។ នេះគឺជាសមត្ថភាពដើម្បីបញ្ជាក់ឲ្យបានច្បាស់អំពីសេចក្តីត្រូវការ និងការយល់ដឹងចំពោះអ្នកដទៃ។

ការចេះដឹងទូទៅគឺជាចំណាប់អារម្មណ៍ក្នុងពិភពលោកខាងក្រៅ។

កូនក្មេងដែលពូកែប្រាស្រ័យទាក់ទង ហើយចង់ដឹងចង់ស្គាល់ដោយរៀនអំពីពិភពលោកដែលនៅជុំវិញខ្លួនគេ គឺជាកូនក្មេងដែលប្រុងប្រៀបខ្លួនដើម្បីធ្វើឲ្យបានល្អទាំងពីរយ៉ាង – គឺនៅសាលារៀន និងគ្រប់ពេលនៅជីវិតរស់នៅ។

## កូនក្មេងសាលាមត្តេយ្យដែលមានជំនាញផ្នែកប្រាស្រ័យទាក់ទងល្អ និងការចេះដឹងទូទៅ:

- និទានរឿង
- លេងល្បែងនឹកស្រមៃ (ដូចជាក្លែងធ្វើជាចោរសមុទ្រ ឬនឹកស្រមៃថាវត្ថុមួយដុំនោះគឺជាប៉មដ៏ខ្ពស់មួយ)
- យល់ដឹងនៅពេលត្រូវបានគេសុំឲ្យធ្វើអ្វីមួយ
- ទាក់ទងឲ្យមនុស្សពេញវ័យដឹង អំពីសេចក្តីត្រូវការរបស់គេដោយប្រើវិធីស្រួលយល់

## របៀបជួយកូនរបស់លោកអ្នកឲ្យចម្រើនលូតលាស់ជំនាញផ្នែកប្រាស្រ័យទាក់ទង និងការចេះដឹងទូទៅ:

- **ស្តាប់កូនរបស់លោកអ្នកដោយគ្មានការបង្អាក់រំខាន**
- **សាកសួរកូនរបស់លោកអ្នកអំពីកិច្ចការក្នុងថ្ងៃរបស់គេ** – សួរសំនួរដែលគ្មានកំណត់ដូចជា “តើអ្នកធ្វើអ្វីនៅខាងក្រៅ?” ជាជាងសួរថា “តើអ្នកមានការរីករាយទេនៅថ្ងៃនេះ?” ដើម្បីឲ្យកូនរបស់លោកអ្នកអាចនិយាយច្រើនជាងពាក្យ “បាទ /ចាស៎” ឬ “ទេ”។
- **អនុញ្ញាតឲ្យកូនរបស់លោកអ្នកសួរសំនួរច្រើន** – ប្រសិនបើកូនរបស់លោកអ្នកកំពុងសួរសំនួរជាច្រើន មានន័យថាគេចង់ដឹងអំពីពិភពលោក។ គេកំពុងសួរលោកអ្នក ដ្បិតអីគេជឿទុកចិត្តថាលោកអ្នកនឹងប្រាប់គេអំពីអ្វីដែលគេចង់ដឹង។
- **និយាយអំពីការមានអារម្មណ៍** - “តើអ្វីដែលធ្វើឲ្យកូនពិបាកចិត្ត?” នៅពេលអានសៀវភៅជាមួយគ្នា សូមនិយាយអំពីថាតើមនុស្ស ឬតួអង្គក្នុងសៀវភៅប្រហែលជាមានអារម្មណ៍យ៉ាងណាដែរ និងអ្វីដែលគេប្រហែលជាត្រូវការ។
- **អានសៀវភៅជាមួយកូនរបស់លោកអ្នក** ហើយនិយាយអំពីសៀវភៅដែលលោកអ្នកបានអាន។ សាកល្បងភ្ជាប់ទំនាក់ទំនងរវាងបទពិសោធន៍ គំនិត និងសៀវភៅ ឧទាហរណ៍ គេកំពុងបរិភោគនុំប៉័ងសាន់វិចលាបជាមួយ vegemite ខ្ញុំឆ្ងល់ថាតើគេនឹងបំបាំងខ្លួនបាត់ដូចនៅក្នុងសៀវភៅ *Possum Magic* ដែរឬទេ។
- **ច្រៀងចំរៀងជាមួយគ្នា** សូត្រពាក្យចុងចួន និងនិយាយកំប្លែងផ្តេសផ្តាស់។
- **លេងល្បែងក្លែងខ្លួន និងនឹកស្រមៃ** – ប្រហែលជាត្រូវប្រើសម្លៀកបំពាក់ឲ្យហ៊ឺហា ឬវត្ថុដទៃទៀតក្នុងផ្ទះ។ បណ្តោយឲ្យគេលេងជាមួយប្រដាប់ក្មេងលេង និងសម្ភារៈខុសៗគ្នា (គ្រាប់អង្កាំ ដីឥដ្ឋ ស្លឹកឈើ ទំពក់ ឬស្នឹងដុំវត្ថុ)។
- **លើកទឹកចិត្តកូនរបស់លោកអ្នក** – ការកោតសរសើរល្អៗចំពោះការប៉ុនប៉ងរបស់កូនលោកអ្នកនឹងជួយគេនៅក្នុងការរៀនប្រាស្រ័យទាក់ទង។ ការសើចចំអកចំពោះកំហុសរបស់គេ នឹងពុំជួយលើកទឹកចិត្តគេឲ្យខិតខំឡើយ។

- **សូមដឹងអំពីកិច្ចការទាំងឡាយដែលមានសារៈសំខាន់ចំពោះកូនរបស់លោកអ្នក** – សាកសួរអំពីមិត្តភក្តិ ប្រដាប់ក្មេងលេង ខ្សែភាពយន្ត ឬសៀវភៅដែលចូលចិត្តជាងគេ។
- **ផ្តល់នូវបទពិសោធន៍** - ទៅផ្សារទិញឥវ៉ាន់ ទៅបណ្ណាល័យ ឬទៅសួនឧទ្យានជាមួយគ្នា ឬគូររូប និងផាត់ពណ៌ជាមួយគ្នា ទាំងអស់នេះគឺជាឱកាសសំរាប់ធ្វើឲ្យចម្រើនលូតលាស់ដល់ជំនាញផ្នែកប្រាស្រ័យទាក់ទង និងការចេះដឹងទូទៅ។
- **បរិភោគអាហារពេលល្ងាចជាមួយគ្នាជាគ្រួសារ** – នេះគឺជាពេលសំខាន់សំរាប់ឲ្យសមាជិកគ្រួសារទាំងអស់ជជែកគ្នាអំពីកិច្ចការក្នុងថ្ងៃរបស់គេ។ សូមដាក់បញ្ចូលកូនរបស់លោកអ្នក ទៅក្នុងការសន្ទនាជាមួយមនុស្សពេញវ័យផងដែរ។
- **រក្សាកំរិតមើលទូរទស្សន៍ លេងខុមព្យូធើរ និងល្បែងវីឌីអូ** – ការនេះនឹងឲ្យកូនរបស់លោកអ្នកមានពេលកាន់តែច្រើនដើម្បីបានបទពិសោធន៍មែនទែនសំរាប់ជជែកគ្នា។ ការប្រើខុមព្យូធើរ ការមើលទូរទស្សន៍ ឬឌីវីឌី ទោះបីវាជារបស់សំរាប់អប់រំក្តីនឹង ពុំជួយកូនរបស់លោកអ្នករៀនប្រាស្រ័យទាក់ទងឡើយ។
- **កូនក្មេងរៀនអំពីវត្ថុខុសៗគ្នា ពីមនុស្សផ្សេងៗគ្នា** – ដូច្នេះហើយសូមទៅសួរសុខទុក្ខមិត្តភក្តិ និងគ្រួសារ ទទួលរាក់ទាក់ឪពុកម្តាយក្មេងដទៃ ទៅរួមក្នុងក្រុមក្មេងលេងចូលគ្នា។
- **វាត្រូវការមនុស្សមួយភូមិ ដើម្បីចិញ្ចឹមកូនក្មេងម្នាក់** – ដូច្នេះ សូមប្រើប្រាស់កិច្ចបំរើក្នុងសហគមន៍របស់លោកអ្នក ដូចជាពេលម៉ោងនិទានរឿងនៅក្នុងបណ្ណាល័យរបស់លោកអ្នក សួនឧទ្យាន សារៈមន្ទីរ អាងហែលទឹក សាលាមត្តេយ្យ។ល។
- **លោកអ្នកពុំចាំបាច់ជាអ្នកមាន ដើម្បីឲ្យកូនរបស់លោកអ្នកមានបរិស្ថានដែលសម្បូរដោយការរៀនសូត្រឡើយ** - ប្រដាប់ក្មេងលេង និងសៀវភៅអាចខ្ចីបានពីបណ្ណាល័យ។ ជាញឹកញាប់មានព្រឹត្តិការណ៍សំរាប់កូនក្មេងដោយឥតគិតថ្លៃនៅក្នុងសហគមន៍របស់លោកអ្នក – សូមអានសារពត៌មានប្រចាំតំបន់របស់លោកអ្នកដើម្បីរកឲ្យដឹង។
- **និយាយទៅកាន់កូនរបស់លោកអ្នក ជាភាសាមួយដែលលោកអ្នកស្រួលប្រើបំផុត** – ការនេះនឹងធ្វើឲ្យប្រាកដថាគេកំពុងរៀនចេះភាសាមួយបានល្អ។ សូមជួយកូនរបស់លោកអ្នកដើម្បីចាប់ផ្តើមរៀនភាសាអង់គ្លេស មុនពេលគេចាប់ផ្តើមចូលសាលារៀន ដោយការចុះឈ្មោះគេនៅសាលាមត្តេយ្យ ឬកន្លែងថែទាំកូនក្មេង។
- **សប្បាយរីករាយក្នុងពេលដ៏រំភើបនេះជាមួយកូនរបស់លោកអ្នក។**



